# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៥០១ ព.ណ..ក.ណ.ប

ថ្ងៃអង្គារ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២៣

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឱ្យបានជ្រាបថា ដើម្បីកាត់បន្ថយឯកសារមិនចាំបាច់សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងផ្តល់កិច្ចសម្រួលការចុះបញ្ជីម៉ាក ក្រសួងពាណិជ្ជកម្មស្នើឱ្យអ្នកដាក់ពាក្យត្រូវប្រើប្រាស់ពាក្យស្នើសុំតែមួយគត់សម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ ដែលអនុលោមតាមមាត្រា១០ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវអនុវត្តតាមសេចក្តីជូនដំណឹង ចាប់ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងនេះតទៅ ។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469